

រួមគ្នាស្វែងយល់ពីជំងឺ
ផ្តាសាយបក្សី
ចំពោះព័ត៌មានបន្ថែម សូមទាក់ទង
➤ក្រសួងកសិកម្ម រុក្ខាប្រមាញ់
និង នេសាទ : ០១២-៨៣៣-៧៩៥ ០១២-២១៤-៩៧០
➤ក្រសួងសុខាភិបាល : ០១២-៤៨៨-៩៨១ ០១២-៨៣៦-៨៦៨
From the People of Japan

# មាតិកា


១- តើជំងឺផ្តាសាយបក្សី គឺជាអ្វី? ទំព័រទី ៣

២- តើរោគសញ្ញាជំងឺផ្តាសាយបក្សីនៅលើបក្សីមានអាការៈ

យ៉ាងដូចម្តេច? ទំព័រទី ៥

៣-តើមនុស្សឆ្លងជំងឺផ្តាសាយបក្សី ដោយរបៀបណា? ទំព័រទី ៧

៤-តើអ្នកជំងឺផ្តាសាយបក្សីមានអាការៈយ៉ាងដូចម្តេច? ទំព័រទី ៨

៥- គួរថែរក្សាអ្នកជំងឺផ្តាសាយបក្សីយ៉ាងដូចម្តេច? ទំព័រទី ៩

៦-តើបង្ការការឆ្លងជំងឺផ្តាសាយបក្សីបានយ៉ាងដូចម្តេច? ទំព័រទី ១១

៧- តើអ្នកចិញ្ចឹម, អ្នកដឹកជញ្ជូន អ្នកសំលាប់ និង អ្នកលក់

សត្វបក្សី ត្រូវបង្ការការឆ្លងយ៉ាងដូចម្តេច? ទំព័រទី ១៤

៨- តើអ្នកចំអិនអាហារអាចបង្ការការឆ្លងយ៉ាងដូចម្តេច? ទំព័រទី ១៦

៩- ពេលមានផ្ទុះជំងឺផ្តាសាយរាតត្បាតជាសកល តើអ្នក

ត្រូវធ្វើដូចម្តេច? ទំព័រទី ១៧


ផ្តាសាយ
បក្សី
ជំងឺផ្តាសាយបក្សី
អាចឆ្លងទៅមនុស្ស
តាមរយៈមាន់_ទា
ដែលឈឺ ឬងាប់
ដូច្នេះមិនត្រូវអោយ
កុមារលេង ឬប៉ះពាល់
មាន់_ទា ឬសត្វស្លាប
ផ្សេងៗទៀតឡើយ
ជាពិសេសមាន់_ទា
ដែលឈឺ ឬងាប់។
ចំពោះព័ត៌មាន
បន្ថែម សូមទាក់ទង
➤ ក្រសួងកសិកម្មរុក្ខា
ប្រមាញ់ និងនេសាទ
012 833 795
012 214 970
➤ ក្រសួងសុខាភិបាល
012 488 981
012 836 868
គ្រោះថ្នាក់!
មាន់-ទាដែលឈឺ ឬ ងាប់
មិនមែនជារបស់សំរាប់លេងទេ
From the People of Japan

# តើជំងឺផ្តាសាយបក្សី គឺ ជាអ្វី?

ជំងឺផ្តាសាយបក្សី គឺជាជំងឺបង្កឡើងដោយវីរុស ដែលបង្កជំងឺលើសត្វស្លាបគ្រប់ប្រភេទ រួមមាន សត្វបក្សីព្រៃ និង សត្វបក្សីស្រុក ។

-សត្វបក្សីព្រៃរួមមាន សត្វហើររស់នៅសេរីលើអាកាសហោះហើរ រយៈចំងាយជិត និង រយៈចំងាយឆ្ងាយដែលអាចឆ្លងពីប្រទេសមួយទៅប្រទេសមួយទៀតហើយអាចឆ្លងរាលដាលជំងឺនៅទូទាំងពិភពលោកទាំងមូល ។

-សត្វស្រុកមានៈ មាន់ ទា ក្ងាន ដែលចិញ្ចឹមតាមកសិដ្ឋាន ឬ តាមគ្រួសារដែលមាននៅក្នុងភូមិ ឃុំ ។ល។

បច្ចុប្បន្ននេះ មេរោគ **Influenza A, H5N1** មានលទ្ធភាពឆ្លងទៅមនុស្សដែលបង្កឱ្យមានជំងឺធ្ងន់ធ្ងរ និងបង្កឱ្យស្លាប់ ( អត្រាស្លាប់លើមនុស្សមានរហូតដល់ទៅ ៥០ ភាគរយ) ។

វីរុស H5N1



សត្វស្លាបព្រៃអាចឆ្លងវីរុសនេះ ទោះវាមិនសូវបង្កឱ្យមានជំងឺក៏ដោយ តែវាអាចចំលងមកសត្វក្នុងស្រុក ដោយវាហើរមកជិតសត្វស្រុក ឬ វាបញ្ចេញតាមលាមកដែលវីរុសនៅក្នុងលាមកនោះរីកដុះដាល ហើយចំលងមកសត្វស្រុក។

ចំពោះសត្វបក្សីស្រុកស្ទើរគ្រប់ប្រភេទទាំងអស់ (លើកលែង ទា និងបក្សីទឹកផ្សេងៗទៀត) ពេលដែលបានឆ្លងវីរុសនេះរមែងតែងតែបណ្តាលឱ្យឈឺភាគច្រើន ក្រោយមកវានឹងវិវត្តន៏ជាជំងឺធ្ងន់ធ្ងរ និងងាប់ ដែលមានអត្រាខ្ពស់ ប៉ុន្តែសត្វទា និងសត្វបក្សីទឹកដែលមានផ្ទុកមេរោគផ្តាសាយបក្សី អាចចំលងជំងឺ តែមិនមានបង្ហាញរោគសញ្ញាអ្វីទ្បើយ។

**សត្វស្លាបព្រៃចំលងមកសត្វស្លាបស្រុក និង មកមនុស្ស**



# តើរោគសញ្ញាជំងឺផ្តាសាយបក្សី នៅលើបក្សី មានអាការៈយ៉ាងដូចម្តេច?

រោគសញ្ញាមួយចំនួននៃជំងឺផ្តាសាយបក្សីដែលកើតនៅលើបក្សី មានដូចជាៈ

-សំកុកមិនស៊ីចំណី

-ក្បាលជាំពណ៌ស្វាយ ហើមក្បាល ត្របកភ្នែក សិរ ណង់ និងជើង

-ប្រកាច់មុនពេលងាប់ រោមបះ ស្នាមជាំឈាមនៅជើង និងពោះ

-សត្វងាប់ភ្លាមៗ និងងាប់ច្រើន

-ដាមឈាមផ្នែកក្រោមស្បែក និង ស្រទាប់ខ្លាញ់ពោះ

-រោគសញ្ញាផ្សេងទៀត ដូចជាៈ ពិបាកដកដង្ហើម ក្អក ហៀរសំបោរ ភាគពីពណ៌បៃតងទៅពណ៌ស

-រយៈពេលសំងំជំងឺមានរហូតដល់ ២១ ថ្ងៃ

## វិធានការ ៖

-បើមានករណីដូចរៀបរាប់ខាងលើត្រូវប្រញាប់រាយការណ៍ជូនមន្ត្រីបសុពេទ្យ ឬភ្នាក់ងារសុខភាពភូមិដែលនៅជិតអ្នកបំផុត។

-ក្នុងកាលៈទេសៈនេះ ហាមទិញលក់ និងប៉ះពាល់ជាបណ្តោះអាសន្ន។

-ហាមឃាត់ចលនាបក្សី ចេញ-ចូល ក្នុងតំបន់ដែលផ្ទុះជំងឺ ។

-សំលាប់បក្សី ក្នុងកសិដ្ឋាន ឬតំបន់ដែលមានផ្ទុះជំងឺ ។

-ធ្វើការរំងាប់មេរោគ ទ្រុង និងសំភារៈប្រើប្រាស់ផ្សេងៗ ។



ក្បាលឡើងពណ៌ស្វាយ



សិរ និង ណង់ពណ៌ស្វាយ



ហើមក្បាល សិរនិងណង់ហើមប៉ោង



ជាំឈាមផ្នែកជើង



ស្នាមជាំឈាម



ជាំឈាមផ្នែកគ្រឿងក្នុង
ជាពិសេសនៅស្រទាប់ខ្លាញ់

# តើមនុស្សឆ្លងជំងឺផ្តាសាយបក្សីដោយរបៀបណា?

មនុស្សភាគច្រើនឆ្លងជំងឺផ្តាសាយបក្សីតាមរយៈការប៉ះពាល់ផ្ទាល់ជាមួយបក្សីដែលឈឺ ឬងាប់ ។ ការប៉ះពាល់នោះរួមមាន :

-ការប៉ះពាល់ជាមួយមេរោគជំងឺផ្តាសាយបក្សីនៅក្នុងច្រមុះ, ទឹកមាត់ ឈាម និងលាមករបស់សត្វបក្សីដែលឈឺ ឬ ងាប់នៅក្នុងបរិស្ថានដែលមានមេរោគផ្តាសាយបក្សីសាយភាយនៅទីកន្លែងនោះ

-ការឆ្លងមកមនុស្សតាមរយៈប្រឡាក់នៅលើដៃ និងសំភារៈប្រើប្រាស់

-ចូលមកក្នុងខ្លួនមនុស្សតាមរយៈ ផ្លូវដង្ហើម និងភ្នែក

-មិនមានការឆ្លងមេរោគជំងឺផ្តាសាយបក្សីពីការទទួលទានអាហារ សាច់ និងស៊ុតបក្សី ព្រៃ ឬ ស្រុកដែលចំអិនឆ្អិនល្អទេ ប៉ុន្តែការរៀបចំ និងការសំលាប់សត្វ អាចប្រឈមនឹងការគ្រោះថ្នាក់ខ្ពស់ ។



**ចំអិនអាហារឱ្យបានឆ្អិនល្អ**

# តើអ្នកជំងឺផ្តាសាយបក្សីមានអាការៈយ៉ាងដូចម្តេច?

ក្រោយពីបានទទួលមេរោគផ្តាសាយបក្សីក្នុងចន្លោះពី ១ ទៅ ៧ ថ្ងៃ អ្នកជំងឺនឹងមានអាការៈស្រដៀងនឹងជំងឺផ្តាសាយធម្មតាដែរ គឺមានគ្រុនក្តៅខ្លាំង ឈឺក្បាល រួយដៃជើង អស់កំលាំង ឈឺ ក ក្អក ហៀរសំបោរ ទឹកភ្នែកហូរ តែប្រការសំខាន់គឺត្រូវចងចាំសញ្ញាសំខាន់ៗដោយសង្ខេបដូចខាងក្រោមនេះ :

- គ្រុនក្តៅ (លើស ៣៨ អង្សារសេ)
- សញ្ញាផ្លូវដង្ហើមដូចជា : ក្អក ដកដង្ហើមថប់ៗ ឬ ពិបាកដកដង្ហើម
- ធ្លាប់មានប៉ះពាល់ជាមួយសត្វបក្សីស្រុក ឬ ព្រៃ ឈឺ ឬ ងាប់ ក្នុងកំឡុងពេល ៧ ថ្ងៃមុន



អ្នកជំងឺផ្តាសាយបក្សីឈឺធ្ងន់កំពុងពិនិត្យព្យាបាល

# គួរថែរក្សាអ្នកជំងឺគ្រុនផ្តាសាយបក្សីយ៉ាងដូចម្តេច?

បើសិនជាអ្នកសង្ស័យថានរណាម្នាក់មានជំងឺផ្តាសាយបក្សី សូមបងប្អូនអនុវត្តន៍នូវវិធានការដូចខាងក្រោមនេះ :

- បញ្ជូនអ្នកជំងឺទៅមណ្ឌលសុខភាព ឬ មន្ទីរពេទ្យបង្អែកដែលនៅជិតបំផុតដើម្បីពិនិត្យព្យាបាលឱ្យទាន់ពេលវេលា
- សូមកុំផ្តល់ឱសថអាស្ពីរីនដល់អ្នកជំងឺជាកុមារ
- នៅពេលថែទាំអ្នកជំងឺត្រូវជៀសវាងការប៉ះពាល់ជិតស្និទ្ធជាមួយអ្នកជំងឺដូចជា ការអោបរឹ ថើបជាដើម។
- សូមណែនាំដល់អ្នកជំងឺអោយពាក់ម៉ាស់ ឬប្រើក្រម៉ាគ្របច្រមុះ និងមាត់ ។ចំពោះអ្នកថែទាំក៏ត្រូវពាក់ម៉ាស់ ឬក្រម៉ា ការពារខ្លួនឯងផងដែរ
- ឬទំនាក់ទំនងទូរស័ព្ទលេខ :

**O ០១២ ៤៨៨ ៩៨១**

**O ០១២ ៨៣៦ ៨៦៨**

**O ០១២ ៨៣៣ ៧៩៥**

**O ០១២ ២១៤ ៩៧០**




បញ្ជូនអ្នកសង្ស័យកើតជំងឺផ្តាសាយបក្សីទៅមណ្ឌលសុខភាព

# តើបង្ការការឆ្លងជំងឺផ្តាសាយបក្សីបានយ៉ាងដូចម្តេច?

- ត្រូវរាយការណ៍ជាបន្ទាន់ដល់ភ្នាក់ងារសុខភាពសត្វភូមិ ឬបសុពេទ្យដែលនៅជិតអ្នកបំផុត ប្រសិនបើឃើញមានសត្វបក្សីងាប់ខុសធម្មតានៅក្នុងភូមិ ។
- មិនត្រូវរើសយកមាន់ រឺទាដែលមានជំងឺ រឺងាប់ដោយយថាហេតុនៅក្នុងភូមិមកធ្វើជាអាហារនោះទេ។
- មិនត្រូវអោយកុមារប៉ះពាល់មាន់ ទា និង សត្វស្លាបផ្សេងៗទៀតឡើយជាពិសេសសត្វស្លាបដែលឈឺ រឺងាប់ ។
- ហាមកុំឱ្យប្រជាជនទៅកន្លែងដែលមានជំងឺផ្តាសាយបក្សីកំពុងតែរាតត្បាត បើពុំមានភារកិច្ចចាំបាច់ ។
- ឧស្សាហ៍លាងដៃ និង សំអាតខ្លួនប្រាណឱ្យបានញឹកញាប់ ព្រោះវាអាចបង្ការការឆ្លងមេរោគចូលក្នុងរាងកាយ ក្នុងនោះរួមទាំងមេរោគផ្តាសាយបក្សីផងដែរ ។
- សត្វទាអាចជាអ្នកចំលងមេរោគ ទោះបីសត្វទាទាំងនោះមើលទៅមានសុខភាពល្អក៏ដោយ ។



## មិនត្រូវចាប់មាន់លេង ឬ ចូលរួមទស្សនាជល់មាន់

## នៅកន្លែងដែលគ្មានអនាម័យ និងមិនមានការត្រួតពិនិត្យពីបសុពេទ្យ

- បង្រៀនក្មេងលាងដៃរាល់ពេលក្រោយ ជូតសំបោរ ឬចាប់កាន់សត្វចិញ្ចឹមគ្រប់ប្រភេទ និង លាងដៃមុនរាល់ទទួលទានអាហារ
- បរិភោគអាហារសាច់សត្វស្លាប និង ស៊ុតដែលរៀបចំចំអិនអោយឆ្អិនល្អ (ឆ្អិនគ្រប់ផ្នែកទាំងអស់នៃអាហារចំអិន)
- ហាមក្មេងកុំឱ្យចូលរួមទស្សនាជល់មាន់
- ហាមកុំឱ្យបឺត ឬ ជញ្ជក់ក្បាលមាន់ពេលជល់មាន់
- ពេលកណ្តាស់ ក្អក ត្រូវយកដៃ កន្សែងដៃ ឬ ក្រម៉ាខ្ទប់មុខ ដើម្បីជៀសវាងបាចសាចទៅអ្នកដទៃទៀត។



ឧស្សាហ៍លាងដៃនឹងសាប៊ូ



យកកន្សែងដៃខ្ទប់មុខពេលកណ្ដាស់

# តើអ្នកចិញ្ចឹម, អ្នកដឹកជញ្ជូន អ្នកសំលាប់ និង អ្នកលក់សត្វបក្សីត្រូវបង្ការការឆ្លងយ៉ាងដូចម្តេច?

ត្រូវពាក់ម៉ាស់ ស្បែកជើងកវែង និងស្រោមដៃក្នុងពេល ៖

- ចេញ និងចូល កសិដ្ឋានចិញ្ចឹមសត្វ
- ពេលដឹកជញ្ជូនសត្វបក្សី តាមរថយន្ត ឬ តាមម៉ូតូ
- ពេលដំណើរការសំលាប់សត្វបក្សី ជាអាជីព នៅក្នុងផ្សារ និងទីសាធារណះ
- ជៀសវាងវាសដៃលើមុខ និងភ្នែកខ្លួនឯង

នៅពេលបញ្ចប់សកម្មភាពការងារដូចបានរៀបរាប់ខាងលើ ត្រូវលាងសំអាតដៃជាបន្ទាន់ ហើយត្រូវងូតទឹកសំអាតរាងកាយជាមួយសាប៊ូអោយបានស្អាត។ រាល់សំភារះការពារផ្សេងៗទៀតត្រូវត្រាំទឹកនិងសាប៊ូហើយបោកសំអាត និងហាលថ្ងៃអោយបានត្រឹមត្រូវ។



ត្រូវពាក់ម៉ាស់, ស្រោមដៃ និង ស្បែកជើងកវែងពេលសំលាប់ និង
បោចសត្វមាន់ ទា និង សត្វស្លាបផ្សេងទៀត

# តើអ្នកចំអិនអាហារអាចបង្ការការឆ្លងយ៉ាងដូចម្តេច?

- មិនត្រូវយកសត្វស្លាប់ដែលឈឺ ឬ ងាប់មកធ្វើជាអាហារ
- ត្រូវជ្រើសរើសទិញសាច់បក្សី មាន់ ទា និងស៊ុតពីកន្លែងដែលមានការទទួលខុសត្រូវ និងធានា ឬមកពីប្រភពដែលជឿជាក់ថាគ្មានផ្ទុះជំងឺ និងជ្រើសរើសសាច់មាន់មើលស្រស់ថ្មី គ្មានស្នាមជាំខ្មៅ ចំណែកស៊ុតត្រូវមើលអោយស្រស់ថ្មី គ្មានលាមកជាប់សំបក
- នៅពេលរៀបចំចំអិនអាហារ មិនត្រូវវាសដៃទៅលើច្រមុះ ភ្នែក មាត់

និងសំភារៈផ្សេងៗទៀតដែលមិនចាំបាច់ដូចជា ទូរស័ព្ទដៃជាដើម ។



# ពេលមានផ្ទុះជំងឺផ្តាសាយរាតត្បាតជាសកល តើអ្នកត្រូវធ្វើដូចម្តេច?

បច្ចុប្បន្ននេះ មេរោគជំងឺផ្តាសាយបក្សីមិនទាន់បំលែងខ្លួនវា និងមានលទ្ធភាពចំលងពីមនុស្សទៅមនុស្សនៅឡើយទេ ។ ប៉ុន្តែប្រសិនបើវាមានលទ្ធភាពចំលងពីមនុស្សទៅមនុស្សនោះវានឹងអាចឆ្លងរីករាលដាលជុំវិញពិភពលោក ហើយមនុស្សមួយចំនួននឹងស្លាប់ដោយជំងឺនេះ។ ការឆ្លងរាលដាលពីមនុស្សទៅមនុស្ស នៃមេរោគជំងឺផ្តាសាយបក្សីជុំវិញពិភពលោកនេះត្រូវបាន គេហៅថាការឆ្លងរាលដាលជាសកល។ ដូច្នេះប្រសិនបើការរាតត្បាតនោះកើតឡើង យើងត្រូវអនុវត្តនូវសេចក្តីណែនាំមួយចំនួនដូចខាងក្រោមនេះ :

- ត្រូវរាយការណ៍ជាបន្ទាន់ប្រសិនបើក្នុងកន្លែងណាមួយមានអ្នកជំងឺកើតជំងឺផ្តាសាយច្រើន
- ហាមធ្វើដំណើរទៅកន្លែងដែលមានមនុស្សកកកុញ ឬ កន្លែងដែលមានជំងឺផ្តាសាយច្រើននៅទីនោះ
- បើមានអ្នកទើបតែមកពីតំបន់ផ្ទុះនោះ ត្រូវឱ្យអ្នកនោះលាងសំអាតខ្លួន និងពាក់ម៉ាស់ ហើយនៅឱ្យដាច់ពីសមាជិកគ្រួសារ និង ឱ្យប្រើសំភារះប្រើប្រាស់ដោយឡែក
- ត្រូវលាងដៃជាមួយសាប៊ូ និងទឹកឱ្យបានញឹកញាប់

- ត្រូវប្រើក្រដាសអនាម័យ កន្សែងដៃ ឬ ក្រមា ខ្ទប់ច្រមុះ និងមាត់នៅពេលក្អក ឬកណ្តាស់ និងបោះចោលក្រដាសអនាម័យដោយប្រុងប្រយ័ត្ន និងបោកគក់ កន្សែង ដៃ ឬក្រមា ជាមួយសាប៊ូ និងទឹករួចហាលកណ្តាលថ្ងៃឱ្យស្ងួតល្អ
- ត្រូវប្រាប់ទៅអ្នកជិតខាង សាច់ញាតិ ដើម្បីរកវិធីព្យាបាលនៅផ្ទះ ឬទៅព្យាបាលនៅមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក ដែលជិតបំផុត ឬ ក៏ទៅកន្លែងព្យាបាលបណ្តោះអាសន្នដែលរៀបចំឡើងដោយអាជ្ញាធរមូលដ្ឋាន។



អ្នកជំងឺផ្តាសាយជាច្រើនកំពុងសំរាកព្យាបាលក្នុងពេលការរាតត្បាតជំងឺផ្តាសាយជាសកល ក្នុងឆ្នាំ ១៩១៨_១៩១៩

# ជំងឺផ្តាសាយបក្សី

ជំងឺផ្តាសាយបក្សីជាជំងឺឆ្លង ដែលអាចសំលាប់មាន់-ទាយ៉ាងច្រើនសន្ធឹក សន្ធាប់ក្នុងរយៈពេលដ៏ខ្លី។ ជំងឺនេះអាចឆ្លងពីសត្វមកមនុស្ស ហើយអាចបណ្តាលអោយស្លាប់។ មកទល់ពេលនេះ មានប្រជាពលរដ្ឋកម្ពុជាចំនួន ៦នាក់ហើយ ដែលស្លាប់ដោយសារជំងឺនេះ។

## វិធីបង្ការជំងឺផ្តាសាយបក្សី

១- មិនត្រូវអោយកុមារលេង ឬប៉ះពាល់មាន់-ទា ឬសត្វស្លាបផ្សេងៗទៀតឡើយ ជាពិសេសមាន់-ទាដែលឈឺ ឬងាប់។

២- សូមលាងដៃអោយបានស្អាតជាមួយសាប៊ូ ឬផេះក្រោយពេលប៉ះពាល់មាន់-ទា។

៣- សាច់មាន់-ទា និងពងរបស់វា ត្រូវចំអិនអោយឆ្អិនល្អសព្វកន្លែង ធ្វើយ៉ាងណាកុំអោយមានឈាម ឬកន្លែងណាមួយដែលនៅឆៅ។

៤- មិនត្រូវយកមាន់-ទា ដែលឈឺឬងាប់ដោយសារជំងឺ មករៀបចំធ្វើជាអាហារ។

៥- បើមានមាន់-ទា ឈឺ ឬងាប់ត្រូវរាយការណ៍ជាបន្ទាន់ដល់ពេទ្យសត្វ ឬទូរស័ព្ទទៅលេខ ០១២-២១៤-៩៧០ ឬ ០១២-៨៣៣-៧៩៥។

៦- បើសង្ស័យថាមានជំងឺផ្តាសាយបក្សីលើមនុស្ស សូមបញ្ជូនអ្នកជំងឺទៅជួបគ្រូពេទ្យជាបន្ទាន់ ឬទូរស័ព្ទទៅលេខ ០១២-៤៨៨-៩៨១ ឬ ០១២-៨៣៦-៨៦៨។

From
the People of Japan


សូមលាងដៃ
ឱ្យបានញឹកញាប់
ជាមួយសាប៊ូ
ឬផេះ
ក្រោយពេលប៉ះពាល់
មាន់-ទា
(សំគាល់ :  សូមកុំប៉ះពាល់មាន់-ទា
ប្រសិនបើគ្មានការចាំបាច់ទេ។ ជាពិសេស
សូមកុំអោយកុមារនៅក្បែរមាន់-ទា)
ក្រោយពេលក្អក ឬ កណ្តាស់
ក្រោយពេលបន្ទោរបង់
មុនពេលទទួលទានអាហារ
ដៃស្អាត =
សុខភាពល្អ
ចំពោះព័ត៌មានបន្ថែម   សូមទាក់ទង
➤ក្រសួងកសិកម្ម រុក្ខាប្រមាញ់
និង នេសាទ :    ០១២-៨៣៣-៧៩៥   ០១២-២១៤-៩៧០
➤ក្រសួងសុខាភិបាល : ០១២-៤៨៨-៩៨១   ០១២-៨៣៦-៨៦៨
From
the People of Japan

# ប្រតិទិនឆ្នាំ ២០០៦ Calendar 2006

### មករា

| អ | ច | អ | ព | ព | ស | ស |
|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 |
| 8 | 9 | 10 | 11 | 12 | 13 | 14 |
| 15 | 16 | 17 | 18 | 19 | 20 | 21 |
| 22 | 23 | 24 | 25 | 26 | 27 | 28 |
| 29 | 30 | 31 | | | | |

### កុម្ភៈ

| អ | ច | អ | ព | ព | ស | ស |
|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4 |
| 5 | 6 | 7 | 8 | 9 | 10 | 11 |
| 12 | 13 | 14 | 15 | 16 | 17 | 18 |
| 19 | 20 | 21 | 22 | 23 | 24 | 25 |
| 26 | 27 | 28 | | | | |

### មិនា

| អ | ច | អ | ព | ព | ស | ស |
|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4 |
| 5 | 6 | 7 | 8 | 9 | 10 | 11 |
| 12 | 13 | 14 | 15 | 16 | 17 | 18 |
| 19 | 20 | 21 | 22 | 23 | 24 | 25 |
| 26 | 27 | 28 | 29 | 30 | 31 | |

### មេសា

| អ | ច | អ | ព | ព | ស | ស |
|---|---|---|---|---|---|---|
| | | | | | | 1 |
| 2 | 3 | 4 | 5 | 6 | 7 | 8 |
| 9 | 10 | 11 | 12 | 13 | 14 | 15 |
| 16 | 17 | 18 | 19 | 20 | 21 | 22 |
| 23 | 24 | 25 | 26 | 27 | 28 | 29 |
| 30 | | | | | | |

### ឧសភា

| អ | ច | អ | ព | ព | ស | ស |
|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 |
| 7 | 8 | 9 | 10 | 11 | 12 | 13 |
| 14 | 15 | 16 | 17 | 18 | 19 | 20 |
| 21 | 22 | 23 | 24 | 25 | 26 | 27 |
| 28 | 29 | 30 | 31 | | | |

### មិថុនា

| អ | ច | អ | ព | ព | ស | ស |
|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 |
| 4 | 5 | 6 | 7 | 8 | 9 | 10 |
| 11 | 12 | 13 | 14 | 15 | 16 | 17 |
| 18 | 19 | 20 | 21 | 22 | 23 | 24 |
| 25 | 26 | 27 | 28 | 29 | 30 | |

### កក្កដា

| អ | ច | អ | ព | ព | ស | ស |
|---|---|---|---|---|---|---|
| | | | | | | 1 |
| 2 | 3 | 4 | 5 | 6 | 7 | 8 |
| 9 | 10 | 11 | 12 | 13 | 14 | 15 |
| 16 | 17 | 18 | 19 | 20 | 21 | 22 |
| 23 | 24 | 25 | 26 | 27 | 28 | 29 |
| 30 | 31 | | | | | |

### សីហា

| អ | ច | អ | ព | ព | ស | ស |
|---|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 | 5 |
| 6 | 7 | 8 | 9 | 10 | 11 | 12 |
| 13 | 14 | 15 | 16 | 17 | 18 | 19 |
| 20 | 21 | 22 | 23 | 24 | 25 | 26 |
| 27 | 28 | 29 | 30 | 31 | | |

### កញ្ញា

| អ | ច | អ | ព | ព | ស | ស |
|---|---|---|---|---|---|---|
| | | | | | 1 | 2 |
| 3 | 4 | 5 | 6 | 7 | 8 | 9 |
| 10 | 11 | 12 | 13 | 14 | 15 | 16 |
| 17 | 18 | 19 | 20 | 21 | 22 | 23 |
| 24 | 25 | 26 | 27 | 28 | 29 | 30 |

### តុលា

| អ | ច | អ | ព | ព | ស | ស |
|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 |
| 8 | 9 | 10 | 11 | 12 | 13 | 14 |
| 15 | 16 | 17 | 18 | 19 | 20 | 21 |
| 22 | 23 | 24 | 25 | 26 | 27 | 28 |
| 29 | 30 | 31 | | | | |

### វិច្ឆិកា

| អ | ច | អ | ព | ព | ស | ស |
|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4 |
| 5 | 6 | 7 | 8 | 9 | 10 | 11 |
| 12 | 13 | 14 | 15 | 16 | 17 | 18 |
| 19 | 20 | 21 | 22 | 23 | 24 | 25 |
| 26 | 27 | 28 | 29 | 30 | | |

### ធ្នូ

| អ | ច | អ | ព | ព | ស | ស |
|---|---|---|---|---|---|---|
| | | | | | 1 | 2 |
| 3 | 4 | 5 | 6 | 7 | 8 | 9 |
| 10 | 11 | 12 | 13 | 14 | 15 | 16 |
| 17 | 18 | 19 | 20 | 21 | 22 | 23 |
| 24 | 25 | 26 | 27 | 28 | 29 | 30 |
| 31 | | | | | | |